# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ
## KINGDOM OF CAMBODIA
## Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ១១៦២ ព.ណ. ភលប

ភ្នំពេញ, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៥

# សេចក្តីជូនដំណឹង

អនុលោមតាមច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពី ការអនុវត្តច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ក្រសួងពាណិជ្ជកម្មមានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន និងភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកទាំងអស់ឲ្យបានជ្រាបថា ដើម្បីផ្តល់សេវាសាធារណៈឲ្យកាន់តែរហ័ស និងមានប្រសិទ្ធភាពខ្ពស់ រាល់ការដាក់ពាក្យស្នើសុំសេវាកម្មសិទ្ធិបញ្ញាទាំងអស់ ដែលស្ថិតនៅក្រោមក្រសួងពាណិជ្ជកម្ម ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ តាមគំរូពាក្យស្នើសុំដែលមានស្រាប់ និងអាចទាញយកបានដោយឥតគិតថ្លៃពីគេហទំព័រកម្មសិទ្ធិបញ្ញា www.cambodiaip.gov.kh និងត្រូវផ្តិតមេដៃ ឬចុះហត្ថលេខា និងបោះត្រា ដោយអ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ។

ចំពោះពាក្យស្នើសុំចុះបញ្ជីម៉ាកសាជាថ្មី និងសេចក្តីប្រកាសអំពី ការប្រើប្រាស់ ឬមិនប្រើប្រាស់ម៉ាក ត្រូវធ្វើឡើងតាមកាលកំណត់ ដែលមានចែងក្នុងមាត្រា ១២ និង ១៥ នៃច្បាប់ និងមាត្រា ២១ និង ២២ នៃអនុក្រឹត្យខាងលើ ដែលអាចរកបានក្នុងគេហទំព័រ www.cambodiaip.gov.kh ផងដែរ។

រាល់ពាក្យស្នើសុំត្រូវធ្វើឡើង *ជាទម្រង់ច្បាប់ដើម (Original Form)* ដោយភ្ជាប់មកជាមួយនូវបង្កាន់ដៃបង់ប្រាក់តាមប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម លេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពី សេវាសាធារណៈ និងឯកសារពាក់ព័ន្ធនានាច្បាប់ដើម ឬច្បាប់ចម្លងដែលមានការបញ្ជាក់ពីភាពត្រឹមត្រូវ ។

សេចក្តីជូនដំណឹងនេះ នឹងចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៥ នេះ តទៅ ។

**ក្រសួងពាណិជ្ជកម្ម**